CITY OF LONGBEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១២ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចផ្តល់ព័ត៌មានលម្អិតស្តីពីក្របខ័ណ្ឌនៃការផ្សះផ្សា

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - នៅសប្តាហ៍នេះទីក្រុងឡុងប៊ិចបានប្រកាសផែនការសម្រាប់ "ក្របខ័ណ្ឌសម្រាប់ការផ្សះផ្សានៅឡុងប៊ិច" ដែលត្រូវបានអនុម័តជាឯកច្ឆ័ន្ទដោយក្រុមប្រឹក្សាក្រុង។ ដោយទទួលស្គាល់នូវអត្ថិភាពនិងផលប៉ះពាល់ជាយូរមកហើយនៃការប្រកាន់បុចសាសន៍នៅឡុងប៊ិច និងនៅក្នុងប្រទេសគំនិតផ្តួចផ្តើមនេះនឹងផ្តល់នូវក្របខ័ណ្ឌសម្រាប់ការចូលរួមរបស់សាធារណៈជនក្នុងដំណើរការផ្សះផ្សាការត្រួតពិនិត្យដំណើរការផ្ទៃក្នុងនិងផែនការសកម្មភាពក្នុងតំបន់។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "ការប្រកាន់បុចសាសន៍គឺមាននៅក្នុងស្ថាប័នសាធារណៈទាំងអស់ហើយនោះរួមមានឡុងប៊ិច។ យើងមានឱកាសដើម្បីស្តាប់ពីសហគមន៍ដែលទាមទារការផ្លាស់ប្តូរនិងចាត់វិធានការលើដំណោះស្រាយដើម្បីដោះស្រាយភាពអយុត្តិធម៌ពូជសាសន៍ និងសមធម៌សម្រាប់មនុស្សទាំងអស់។

**ក្របខ័ណ្ឌនៃការផ្សះផ្សាឡុងប៊ិចទាក់ទងនឹងជំហានសំខាន់ៗចំនួនបួន៖**

- **ការទទួលស្គាល់**នូវអត្ថិភាពនិងផលប៉ះពាល់ជាយូរមកហើយនៃការប្រកាន់ពូជសាសន៍នៅឡុងប៊ិចនិងនៅក្នុងប្រទេស។
- **ស្តាប់**ពីរឿងរ៉ាវដែលបានកើតឡើងនិងបទពិសោធន៍នៃភាពអយុត្តិធម៌ខាងពូជសាសន៍វិសមធម៌ ឬគ្រោះថ្នាក់ដែលបានកើតឡើងចំពោះសមាជិកសហគមន៍។

- **កោះហៅប្រជុំ**រវាងភាគីពាក់ព័ន្ធដើម្បីវាយតម្លៃលើយោបល់នានាដែលទទួលបានពីការស្តាប់ ហើយរៀបចំគោលនយោបាយផ្នែកថវិកាធម្មនុញ្ញនិងគំនិតកំណែទម្រង់កម្មវិធី។
- **ចាត់វិធានការ**រហ័សដែលបង្ហាញនូវអនុសាសន៍ភ្លាមៗក្នុងរយៈពេលខ្លីមធ្យមនិងវែងសម្រាប់ឲ្យក្រុមប្រឹក្សាក្រុងធ្វើការពិចារណា។

ចាប់ផ្តើមនៅសប្តាហ៍ក្រោយអ្នករស់នៅទីក្រុងឡុងប៊ិចនឹងមានឱកាសចូលរួមវគ្គស្តាប់ពីសហគមន៍បែបផែនក្រុមដើម្បីចូលរួមផ្តល់គំនិតយោបល់ក្នុងការបង្កើតការផ្លាស់ប្តូរប្រកបដោយអត្ថន័យសម្រាប់គ្រប់ទិដ្ឋភាពនៃវិសមភាពនិងភាពអយុត្តិធម៌ពូជសាសន៍។ វគ្គជាង ១០ វគ្គនឹងត្រូវធ្វើឡើងក្នុងរយៈពេល ២ សប្តាហ៍ខាងមុខដោយអ្នកថ្នាក់ដឹកនាំទីក្រុងនឹងភ្ជាប់ជាមួយនឹងមូលដ្ឋានធំទូលាយនៃអ្នកពាក់ព័ន្ធចម្រុះនៅក្នុងសហគមន៍ជនជាតិស្បែកខ្មៅក៏ដូចជាទីក្រុងឡុងប៊ិចទាំងមូល។

វគ្គស្តាប់នឹងចាប់ផ្តើមនៅថ្ងៃទី ១៨ ខែមិថុនានិងបន្តរហូតដល់ខែកក្កដា។ ដើម្បីអនុលោមតាមបទបញ្ជាសុខភាពបច្ចុប្បន្ននិងវិធានការណ៍រក្សារាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នារបស់ទីក្រុងវគ្គស្តាប់នឹងត្រូវធ្វើតាមអ៊ិនធរណេតនាពេលនេះ។

ព័ត៌មានលំអិតនិងព័ត៌មានចុះឈ្មោះបន្ថែមអាចរកបាននៅលើគេហទំព័ររបស់ការិយាល័យសមធម៌នៃទីក្រុងឡុងប៊ិច។ សមាជិកសហគមន៍ត្រូវបានលើកទឹកចិត្តឱ្យបំពេញការស្ទង់មតិតាមអ៊ិនធរណេតហើយអាចផ្ញើសំណួរយោបល់និងការសាកសួរអំពីរបៀបចូលរួមដោយផ្ញើអ៊ីមែលទៅ៖ EquityLB@longbeach.gov។ រាល់មតិយោបល់នឹងត្រូវពិនិត្យរៀបចំចាត់ចែងទៅជាវិស័យតាមប្រធានបទនិងចែករំលែកជាមួយនឹងអ្នកបង្កើតគោលនយោបាយនិងសាធារណជន។

### ប្រធានបទថ្ងៃនិងពេលវេលានៃវគ្គស្តាប់ដំបូងមានដូចខាងក្រោម៖

### សមធម៌ពូជសាសន៍នៅទូទាំងប្រព័ន្ធទាំងអស់ (រួមមានសុខភាពសេដ្ឋកិច្ចការអប់រំ។ ល។)

June 18, 5:30 p.m. - 7 p.m.

June 30, 5:30 p.m. - 7 p.m.

### វិសាលគមនៃសុវត្ថិភាពរបស់សហគមន៍

July 2, 10 a.m. - 11:30 a.m.

June 24, 5:30 p.m. - 7 p.m.

### សមធម៌ផ្នែកសុខភាព

June 25, 5:30 p.m. - 7 p.m.

July 2, 10 a.m. - 11:30 a.m.

### សមធម៌ពូជសាសន៍ដែលទាក់ទងនឹងលំនៅដ្ឋាននិងភាពគ្មានផ្ទះសម្បែង

June 26, 10 a.m. - 11:30 a.m.

July 1, 5:30 p.m. - 7 p.m.

### សមធម៌ផ្នែកសេដ្ឋកិច្ច

June 29, 10 a.m. - 11:30 a.m.

July 2, 5:30 p.m. - 7 p.m.

### សមធម៌ក្នុងការអប់រំនិងសេវាកម្មយុវជន

June 29, 5:30 p.m. - 7 p.m.

July 3, 10 a.m. - 11:30 a.m.

ក្រុមបុគ្គលិកក្រុងចម្រុះដែលមកពីមន្ទីរផ្សេងៗគ្នាដឹកនាំដោយលោកស្រី Teresa Chandler អនុប្រធានក្រុងបណ្ដោះអាសន្ននៅក្នុងការិយាល័យគ្រប់គ្រងក្រុងនឹងកោះប្រជុំជាមួយអ្នកពាក់ព័ន្ធក្នុងក្រុងដើម្បីវាយតម្លៃលើមតិយោបល់និងជួយរៀបចំគោលនយោបាយថវិកានិងគំនិតកែទម្រង់សម្រាប់ឲ្យក្រុមប្រឹក្សាក្រុងពិចារណាដើម្បីអនុវត្តការកែទម្រង់រចនាសម្ព័ន្ធនៅក្នុងខែកក្កដានិងសីហា។

លោក Tom Modica ប្រធានគ្រប់គ្រងក្រុងបានមានប្រសាសន៍ថា "យើងយល់ថាការប្រកាន់បុចសាសន៍និងការប៉ះទង្គិចរបស់សហគមន៍គឺជាបញ្ហាធ្ងន់ធ្ងរ។ ការឈឺចាប់ដែលយើងបានឃើញពីសហគមន៍របស់យើងគឺជាការពិត។ វាត្រូវការពន្លឺវាត្រូវការការពិភាក្សាហើយវាត្រូវការសកម្មភាព។ ឥឡូវនេះគឺដល់ពេលហើយ។"

អស់រយៈពេលជាច្រើនទសវត្សនៅសហរដ្ឋអាមេរិកនិងនៅឡុងប៊ិចគឺមានប្រវត្តិសាស្រ្តនៃច្បាប់និងការអនុវត្តមិនស្មើភាពគ្នារួមមានការប្រកាន់ក្នុងការជ្រើសរើសការងារការមិនអាចទទួលបានប្រាក់កម្ចីដោយផ្អែកលើបុចសាសន៍និងការកំណត់តំបន់ដោយយោងទៅតាមបុចសាសន៍និងប្រាក់ចំណូលនិងសាលារៀនដែលមានប្រាក់ឧបត្ថម្ភតិចតួចក៏ដូចជាការវិនិយោគមិនគ្រប់គ្រាន់ទៅលើការអប់រំដែលបណ្តាលឱ្យមានវិសមភាពពូជសាសន៍ផ្អែកសុខភាពទ្រព្យសម្បត្តិនិងឱកាសនិងបង្កើតឧបសគ្គជាច្រើនដល់ប្រជាជនស្បែកខ្មៅនិងអ្នកមានចំណូលទាប។

នៅឡុងប៊ិចជម្ងឺរាតត្បាត COVID-19 បានជះឥទ្ធិពលជាពិសេសដល់សហគមន៍ស្បែកខ្មៅ។ ប្រជាជនស្បែកខ្មៅគឺជាចំនួន 13 ភាគរយនៃចំនួនប្រជាជនសរុបតែជនជាតិនេះគឺជាចំនួន 23 ភាគរយនៃអ្នកដែលស្លាប់ដោយសារតែជម្ងឺ COVID-19។ ជនជាតិស្បែកខ្មៅក៏ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដោយសារជម្ងឺហឺត 9.4 ដងច្រើនជាងជនជាតិស្បែកស។ ការបំពុលខ្យល់និងផ្សែងប្រេងម៉ាស៊ូតចេញពីឡានដឹកទំនិញនាវានិងរថភ្លើងបង្កគ្រោះថ្នាក់ដល់សុខភាពយ៉ាងខ្លាំងហើយលំនៅដ្ឋានសម្រាប់ប្រជាជនស្បែកខ្មៅនិងអ្នកមានចំណូលទាបជាធម្មតានៅជាប់នឹងតំបន់ប្រើប្រាស់ដែលមានបញ្ហាទាំងនេះ។

ការលុបបំបាត់វិសមភាពពូជសាសន៍ទាក់ទងនឹងប្រាក់ចំណូលនិងទ្រព្យសម្បត្តិនឹងផ្តល់ផលប្រយោជន៍ដល់គ្រួសារសហគមន៍និងសេដ្ឋកិច្ចក្នុងស្រុកនិងក្នុងតំបន់។ សព្វថ្ងៃនេះប្រាក់ចំណូលជាមធ្យមសម្រាប់កម្មករជនជាតិស្បែកសនៅឡុងប៊ិចមានចំនួនទ្វេដងនៃកម្មករជនជាតិឡាតាំងហើយយ៉ាងហោចណាស់មានចំនួនមួយដងកន្លះច្រើនជាប្រាក់ចំណូលរបស់ជនជាតិស្បែកខ្មៅអាស៊ីអាស៊ីប៉ាស៊ីហ្វិកនិងជនជាតិភាគតិចដទៃទៀត។

ទីក្រុងឡុងប៊ិចមានមោទនភាពជាទីក្រុងមួយក្នុងចំណោមទីក្រុងដែលមានភាពចម្រុះបំផុតនៅក្នុងប្រទេសហើយទីក្រុងឡុងប៊ិចបានប្តេជ្ញាចិត្តដើម្បីអនុវត្តចក្ខុវិស័យរបស់សហគមន៍ដើម្បីធានាថាឡុងប៊ិចនឹងបន្តរីកចម្រើននិងផ្តល់ឱកាសកាន់តែប្រសើរសម្រាប់ទាំងអស់គ្នា។ អ្នកដឹកនាំទីក្រុងបានផ្លាស់ប្តូរវប្បធម៌ពីការអនុវត្តកម្មវិធីដាច់ដោយឡែកទៅរកវិធីសាស្រ្តដែលមានលក្ខណៈជាប្រព័ន្ធនិងសហការគ្នាដើម្បីដោះស្រាយវិសមភាពនៃសេដ្ឋកិច្ចនិងសុខភាពនៅទូទាំងឡុងប៊ិច។

ទីក្រុងឡុងប៊ិចបានបោះជំហានសំខាន់ៗរួចហើយដើម្បីឈានដល់គោលដៅទាំងនេះរួមមាន៖ ការវិនិយោគបណ្តុះបណ្តាលបុគ្គលិក ការបង្កើតការិយាល័យសមធម៌ ការក្លាយជាសមាជិកសម្ព័ន្ធរដ្ឋាភិបាល

ស្ដីពីបុចសាសន៍និងសមធម៌និងការបង្កើតកញ្ចប់ឧបករណ៍សមធម៌។ ទោះយ៉ាងណាក៏ដោយមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើដើម្បីធ្វើសមាហរណកម្មសមធម៌ផ្ទៃក្នុងតាមរយៈការសំរេចចិត្តគោលនយោបាយការអនុវត្តកម្មវិធីនិងថវិកាទាំងអស់របស់ទីក្រុងដើម្បីជួយធានាថាបុគ្គលទាំងអស់អាចឈានដល់កំរិតខ្ពស់បំផុតនៃសុខភាពនិងសក្ដានុពលសម្រាប់ជីវិតជោគជ័យដោយមិនគិតពីសាវតានិងអត្តសញ្ញាណរបស់ពួកគាត់។ ទីក្រុងនៅតែប្ដេជ្ញាបន្តកិច្ចប្រឹងប្រែងទាំងនេះដើម្បីបញ្ចប់ការប្រកាន់បុចសាសន៍នៅឡុងប៊ិច។

សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័ររបស់ការិយាល័យសមធម៌នៃទីក្រុងឡុងប៊ិច។

**អំពីទីក្រុងឡុងប៊ិច**

ជាទីលំនៅដ្ឋាននៃប្រជាជនប្រមាណ ៤៨០,០០០ នាក់ទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់និងជាទីក្រុងច្នៃប្រឌិតដែលផ្ដល់ជូននូវភាពសំបូរបែបនៃពិភពលោកខណៈពេលដែលរក្សាលក្ខណៈបុគ្គលនិងដែលបង្កើតឡើងពីសង្កាត់ផ្សេងៗពីគ្នាដែលបានផ្ដុំនៅតាមបណ្ដោយឆ្នេរសមុទ្រប៉ាស៊ីហ្វិក។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញទីក្រុងឡុងប៊ិចជាលំនៅដ្ឋានរបស់នាវា Queen Mary, អាងចិញ្ចឹមត្រីនៃមហាសមុទ្រប៉ាស៊ីហ្វិក (Aquarium of the Pacific), សារមន្ទីរនិងរោងកុនជាច្រើន, សាលារៀនដែលត្រូវបានវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច, កំពង់ផែឡុងប៊ិច ក៏ដូចជាមន្ទីរផ្សេងៗដែលបានទទួលពានរង្វាន់ជាច្រើនដូចជាមន្ទីរសុខាភិបាល មន្ទីរឧទ្យានការកំសាន្តនិងសមុទ្រ មន្ទីរសេវាកម្មអភិវឌ្ឍន៍ និងមន្ទីរផ្សេងៗទៀត។ ទីក្រុងនេះក៏មានសាកលវិទ្យាល័យនិងមហាវិទ្យាល័យដែលត្រូវបានការគោរពខ្ពស់ ក៏ដូចជាកន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រចំនួន២ មន្ទីរពេទ្យ៥ ទីតាំង៥សម្រាប់លេងហ្គោល សួន១៧០ ឆ្នេរសមុទ្រជាច្រើនម៉ាយល៍ម៉ា ផ្លូវសម្រាប់ជិះកង់ និងកម្មវិធីជិះកង់ដែលមានការចែករំលែក។

សម្រាប់ព័ត៌មានបន្ថែមអំពីទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://longbeach.gov/។ សូមតាមដានទីក្រុងឡុងប៊ិចនៅលើបណ្ដាញសង្គមសម្រាប់ព័ត៌មានថ្មីៗនៅលើ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធូប។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្ត ដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្ដាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #